



# ត្រែង ឬ សុក្រំ?

**គ្រូខយកដើមត្រែងជាច្បាប់ប្រាណ**
**ខារយោបក់ច្រានមិនរលំ**
**រុក្ខជាតិដូចយ៉ាងផ្ទឹកសុក្រំ**
**ខ្យល់ធំបក់ចំគង់រលើង។**

បណ្ដាំមេបាពីព្រេងនាយ
និយាយប្រាយប្រាប់កូនខ្មែរយើង
ធ្វើអ្វីកុំបីតាមទំនើង
ត្រូវចេះចុះឡើងតាមសភាព។
តែខ្ញុំវែងខ្វល់អំពល់ចិត្ត
បើគិតតែគ្រាប់ត្រែងទាប១
ទោរទន់តាមខ្យល់ស្គាល់តែលាភ
រស់នៅរបៀបអែបឡេបឡប។
លុតក្រាបលើកទូលពោលសរសើរ
ចាំតែហៃអើបញ្ជើរអប
ត្រូវខ្យល់ណាខ្លាំងក៏បាក់បប
ខ្លាចខ្លបងងុលតាមខ្យល់នោះ។
ចំណែកដើមផ្ទឹកឬសុក្រំ
ឈរហំមិនឱនមិនក្រាបចុះ
ស៊ូដួលរលំមិនព្រមខុស
ពីធម្មជាតិដុះជាឈើធំ។
ឃើញខ្មៅថាខ្មៅមិនថាស
ឃើញល្អថាល្អមិនបន្លំ
ឈរពាំងរាំងខ្យល់មិនសម្ងំ
ត្រូវគេចំអកថាថោកខ្លៅ។
ដែលខ្ញុំនិយាយស្ដីមកនេះ
ពុំមែនចង់ចេះលើសម៉ែឪ
មាក់ងាយពាក្យចាស់លោកប្រដៅ
តែចិត្តឆ្ងល់នៅទើបថ្លាថ្លែង។
ពេលណាគួរគ្រាប់តាមសុក្រំ
ពេលណាគួរខំគ្រាប់តាមត្រែង?
ព្រះពុទ្ធជាម្ចាស់លោកសម្ដែង
ផ្លូវល្អនោះឯងផ្លូវកណ្ដាល!

ម៉ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី